# ខ្លឹមសារសង្ខេប

# សាលដីកាតុលាការកំពូល ហ្វីលីពីន

**[Oposa et al v. Fulgencio S. Factoran Jr. et al. (G.R. No. 101083)]**

**១.** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចេញដីកាអនុញ្ញាតឲ្យក្រុមកាប់ឈើរយៈពេល ២៥ឆ្នាំ។ សកម្មភាពកាប់ឈើ បានប៉ះពាល់ដល់បរិស្ថាន ខ្យល់ សត្វ ថយចុះចំនួនព្រៃឈើ និងជីវភាពរស់នៅរបស់ប្រជាជន។ ប្រជាជនក៏បារម្ភ ខ្លាចអស់ធនធានសម្រាប់ក្មេងជំនាន់ក្រោយ ដែលមិនទាន់កើតផងដែរ។ ទាំងនេះ ជាមូលហេតុ នាំឲ្យប្រជាជនធ្វើបណ្តឹងរដ្ឋបាល ទៅលោករដ្ឋមន្ត្រី ឲ្យចេញសេចក្តីសម្រេចបញ្ឈប់ និង លែងចេញអាជ្ញាប័ណ្ណផ្សេងទៀត (Timber Cutting Agreement: TCA) **ទំព័រ ១**។

**២.** តុលាការ បានចេញសេចក្តីសម្រេចបដិសេធបណ្តឹង ដោយឈរលើមូលដ្ឋានចំនួនបី៖ **ក.** វាជាបញ្ហាការងាររបស់នីតិប្រតិបត្តិ ដែលតាមទ្រឹស្តី បញ្ហានយោបាយ (political questions) តុលាការគ្មានសមត្ថកិច្ចពិចារណាបណ្តឹងនេះទេ។ **ខ.** អ្នកប្តឹងមិនបានបង្ហាញមូលដ្ឋានបណ្តឹងរឹងមាំ (no cause of action[1]) និង **គ.** កិច្ចសន្យានេះ គឺជាប្រភេទកិច្ចសន្យាអចិន្ត្រៃយ៍ ហាមឃាត់ដោយច្បាប់រដ្ឋធម្មនុញ្ញ មិនអាចកែ ឬលុបបានទេ (permanent contract clause) **ទំព័រ ២**។

**៣.** ប្រជាជន មិនសុខចិត្ត និងបានប្តឹងប្រឆាំងទៅតុលាការកំពូល ដោយអះអាងថា ក្នុងការសម្រេចនេះ ថៅក្រម បានបំពានឆន្ទានុសិទ្ធិ (abuse of discretion) ដែលជាមូលហេតុនាំឲ្យមាន ការពិនិត្យកិច្ចរបស់ថៅក្រមដោយតុលាការជាន់ខ្ពស់ (judicial review)។ តុលាការកំពូល បានទទួលយកបណ្តឹង ថាមានមូលដ្ឋានតាមក្រមរដ្ឋបាល។ មនុស្សជំនាន់ក្រោយ មិនទាន់កើតក៏មានផលប្រយោជន៍ក្នុងរឿងនេះ ដែលតំណាងដោយប្រជាជនជំនាន់នេះ។ បណ្តឹងនេះ ស្ថិតចូលក្នុងបណ្តឹងជាក្រុម (class

---

[1] A cause of action is defined as: ". . . an act or omission of one party in violation of the legal right or rights of the other; and its essential elements are legal right of the plaintiff, correlative obligation of the defendant, and act or omission of the defendant in violation of said legal right." (Marao Sugar Central Co. vs. Barrios, 79 Phil. 666 [1947];

actions) ដែលបង្ហាញថា ក្រុមមនុស្សអ្នកមានប្រយោជន៍ មានលក្ខណៈ ទូលាយរាប់ទាំងមនុស្សមិនទាន់កើតផងដែរ។ ក្រោយទទួលយកបណ្តឹង តុលាការ បានទាមទារឲ្យភាគីដាក់នូវអំណះអំណាង (submission) **ទំព័រ ៩**។

**៤.** តុលាការកំពូល បានលើកសំអាងហេតុ និងបានឆ្លើយនូវបញ្ហាដែលបានចោទឡើង។ បញ្ហានយោបាយ ជារបាំនៃការពិចារណា លែងជាកត្តាហើយ ដោយសារនៅក្នុងសង្គមប្រជាធិបតេយ្យ តុលាការ តាមទ្រឹស្តី check and balance អាចត្រួតពិនិត្យមើលកិច្ចរបស់នីតិប្រតិប្រត្តិ៖ មាត្រា ៧ ផ្នែកទី១ នៃច្បាប់រដ្ឋធម្មនុញ្ញ "***អំណាចតុលាការរាប់បញ្ចូលករណីកិច្ចរបស់តុលាការ ក្នុងការ...ដោះស្រាយនូវទំនាស់...ថាតើមាន ឬមិនមានការបំពានឆន្ទានុសិទ្ធិធ្ងន់ធ្ងរ ដោយផ្នែកណាមួយនៃរដ្ឋាភិបាល..***"។[2] ចៅក្រមជាន់ទាបទំនងជា ធ្វើការហួសដែនសមត្ថកិច្ច ក្នុងការពិចារណា ថាជាប្រភេទកិច្ចសន្យាអចិន្ត្រៃយ៍ ខណៈដែលរដ្ឋមន្ត្រី មិនលើកអំណះអំណាងនេះ នៅចំពោះមុខខ្លួន។ ជាការពិត សិទ្ធិសេរីភាព ចុះកិច្ចសន្យា មិនមានភាពដាច់ខាត (not absolute rights)។ ដូចនេះ កិច្ចសន្យា អាចត្រូវបានកែសម្រួល ឬបញ្ចប់ក្នុងករណីមានផលប៉ះពាល់ដល់ផលប្រយោជន៍ជាតិ។[3] ក្នុងពេលមុន សិទ្ធិបរិស្ថាន ទោះបីមិនបានចែងមានក្នុងច្បាប់ពាក់ព័ន្ធ វាមានកំណើតតាំងពីកំណាក់កំណើតនៃមនុស្សលោក ហើយក្រោយមក

---

[2] "In the case now before us, the jurisdictional objection becomes even less tenable and decisive. The reason is that, even if we were to assume that the issue presented before us was political in nature, we would still not be precluded from resolving it under the expanded jurisdiction conferred upon us that now covers, in proper cases, even the political question. Article VII, Section 1, of the Constitution clearly provides: "Judicial power includes the duty of the courts of justice to settle actual controversies involving rights which are legally demandable and enforceable, and to determine whether or not there has been a grave abuse of discretion amounting to lack or excess of jurisdiction on the part of any branch or instrumentality of the Government.", ***para.3***.

[3] ". . . Provided, that when the national interest so requires, the President may amend, modify, replace or rescind any contract, concession, permit, licenses or any other form of privilege granted herein . . .", **p. 16.**

សិទ្ធិនេះ ត្រូវបានចែងក្នុងធម្មនុញ្ញនៃប្រទេសនេះ[4] ហើយរដ្ឋាភិបាល និងស្ថាប័នរបស់ខ្លួន មានកាតព្វកិច្ចថែរក្សាបរិស្ថានសម្រាប់ជំនាន់នេះ និងជំនាន់ក្រោយទៀត។

**កំណត់សំគាល់**៖ **ក.** បញ្ហានយោបាយនេះ ជារបាសម្រាប់តុលាការ។ ក្នុងន័យដើម បញ្ហានេះមានដូចជាការសម្រេចធ្វើសង្គ្រាម ដែលជាសមត្ថកិច្ចរបស់នីតិប្រតិបត្តិ។ **ខ.** រឿងនេះបង្ហាញពីទំនាស់ផលប្រយោជន៍សេដ្ឋកិច្ចរបស់រដ្ឋ និង ការការពារបរិស្ថាន មិនត្រឹមតែសម្រាប់ មនុស្សជំនាន់នេះទេ គឺសម្រាប់ជំនាន់ក្រោយផងដែរ សូម្បីពួកគេមិនទាន់កើតក្តី។ តុលាការបានសម្រេចលើកកម្ពស់ប្រយោជន៍ទី២ ហើយផ្តល់ឋានៈក្នុងការដាក់ពាក្យបណ្តឹង (legal standing) ដល់មនុស្សមិនទាន់កើត។ **គ.** តុលាការប្រើពាក្យ “បណ្តឹងជាក្រុម” (class action) ។ ក្នុងច្បាប់ស្តីពី ការការពារអ្នកប្រើប្រាស់ កម្ពុជាទំនងជាទទួលស្គាល់ បណ្តឹងប្រភេទនេះផងដែរ ដោយសារ ជនរងគ្រោះនៃទង្វើ ដូចជា ពុលអាហារអាចមានច្រើន ដែលទាមទារឲ្យមានអ្នកតំណាងដាក់ពាក្យបណ្តឹងជំនួស។ **ឃ.** សិទ្ធិធ្វើកិច្ចសន្យា មិនមែនជាសិទ្ធិដាច់ខាតទេ។

[4] "SEC. 16. The State shall protect and advance the right of the people to a balanced and healthful ecology in accord with the rhythm and harmony of nature."